# مدرسة اهل البيت

# សាលា
# អាស់លុល-បៃត៍

## សៀវភៅ ប្រវត្តិសាស្រ្ត (تَارِيْخ) ថ្នាក់ទី ១

(អាយុ ៥-៦ ឆ្នាំ)

قَالَ اَلنَّبِيُّ صَلَّى اللّٰهُ عَلَيْهِ وَ آلِهِ : طَلَبُ اَلْعِلْمِ فَرِيضَةٌ عَلَى كُلِّ مُسْلِمٍ وَ مُسْلِمَةٍ (بحار الأنوار ج ١ ص ١٧٧)

ព្រះសាស្ដាﷺមានព្រះវចនៈថា៖ "ស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចលើមុស្លីមប្រុសស្រីគ្រប់រូប ។"

## សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ សៃតន لعن الله ........................................ ៥

មេរៀនទី ២ ព្រះសាស្ដាមូហាំម៉ាដ់ អាល់-មុស្តហ្វា صلى الله عليه وآله وسلم ........................................ ៨

មេរៀនទី ៣ ប៊ីប៊ី ហ្វាទីម៉ាស់ អាស់ស្សាស់រ៉អ៊ុ سلام الله عليها ........................................ ១២

មេរៀនទី ៤ អ៊ីម៉ាំអាលី صلوات الله عليه والسلام ........................................ ១៥

មេរៀនទី ៥ អ៊ីម៉ាំហាសាន់ صلوات الله عليه والسلام ........................................ ១៨

មេរៀនទី ៦ អ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام ........................................ ២១

មេរៀនទី ៧ អ៊ីម៉ាំ អាលី សៃនុល-អាប៊ីឌីន صلوات الله عليه والسلام ........................................ ២៥

មេរៀនទី ៨ អ៊ីម៉ាំ មូហាំម៉ាដ់ អាល់-បាកៀរ صلوات الله عليه والسلام ........................................ ២៨

មេរៀនទី ៩ អ៊ីម៉ាំ យ៉ាក់ហ្វារ អាស់-សាឌិក صلوات الله عليه والسلام ........................................ ៣១

មេរៀនទី ១០ អ៊ីម៉ាំ មូសា អាល់-កាស៊ីម صلوات الله عليه والسلام ........................................ ៣៤

មេរៀនទី ១១ អ៊ីម៉ាំ អាលី អារ-រីដ៏ صلوات الله عليه والسلام ........................................ ៣៧

មេរៀនទី ១២ អ៊ីម៉ាំ មូហាំម៉ាដ់ អាត់-តាគី صلوات الله عليه والسلام ........................................ ៤០

មេរៀនទី ១៣ អ៊ីម៉ាំ អាលី អាន់-ណាគី صلوات الله عليه والسلام ........................................ ៤៣

មេរៀនទី ១៤ អ៊ីម៉ាំ ហាសាន់ អាល់-អាស់ការី صلوات الله عليه والسلام ........................................ ៤៦

មេរៀនទី ១៥ អ៊ីម៉ាំ មូហាំម៉ាដ់ អាល់-ម៉ាស់ឌី صلوات الله عليه والسلام ........................................ ៤៩

រឿងទេវតាហ្វុតរុសនិងអ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام ........................................ ៥៣

## មេរៀនទី ១

# ស្ហៃតន لعنه الله

មុនបង្កើតមនុស្ស អល់ឡោះហ្វ៊ عز وجل បានបង្កើតសត្វលោកនិងវត្ថុផ្សេងៗដូចជា៖

-ថ្ងៃនិងខែ
-មេឃ
-ដី
-សត្វ
-ដើមឈើ
-ទេវតា
-យ៉ីន

យ៉ីនដូចមនុស្សដែរ យ៉ីនខ្លះល្អ ស្តាប់បង្គាប់អល់ឡោះហ្វ៊ عز وجل យ៉ីនខ្លះទៀតអាក្រក់ មិនស្តាប់បង្គាប់អល់ឡោះហ្វ៊ عز وجل ទេ ។

ស្ហៃតន لعنه الله ជាបុគ្គលល្អប្រសើរណាស់កាលពីដំបូង ហេតុដូច្នេះឯងបានជាអល់ឡោះហ្វ៊ عز وجل ឲ្យវា لعنه الله នៅក្នុងឋានសួគ៌ជាមួយអស់ទេវតា ។ វា لعنه الله បានគោរពសក្ការៈអល់ឡោះហ្វ៊ عز وجل ជានិច្ច ។ អល់ឡោះហ្វ៊ عز وجل បង្កើតពួកយ៉ីនមកពីភ្លើង ។

ក្រោយមកអល់ឡោះហ្វ៊ عز وجل បានសម្រេចព្រះហឫទ័យបង្កើតមនុស្ស ។ ព្រះអង្គ عز وجل បានបង្កើតមនុស្សមកពីដី ។ មនុស្សដំបូងបង្អស់ដែលអល់ឡោះហ្វ៊ عز وجل បានបង្កើតមកគឺព្រះសាស្តា (ណាប៊ី) អាដាំ عليه السلام ។ អល់ឡោះហ្វ៊ عز وجل បានឲ្យសត្វលោកទាំងអស់ដែលនៅក្នុងឋានសួគ៌ក្រាបប្រណិប័តន៍ព្រះសាស្តាអាដាំ عليه السلام តែស្ហៃតន لعنه الله មិនព្រមទេដោយប្រកែកថាខ្លួនវា لعنه الله ត្រូវបង្កើតមកពីភ្លើង អាស្រ័យហេតុនេះវា لعنه الله ប្រសើរជាងព្រះសាស្តាអាដាំ عليه السلام ។ អល់ឡោះហ្វ៊ عز وجل បានប្រាប់វា لعنه الله ថាវា لعنه الله លែងបាននៅក្នុងឋាន

សួគ៌តទៅ វាلعنه اللهនឹងនៅក្នុងឋាននរក នឹងត្រូវដុតកម្ដោចដោយភ្លើងនរក ។

យើងត្រូវស្ដាប់អស់ឡោះហ្វ៍عز وجلជានិច្ច ត្រូវប្រព្រឹត្តខ្លួនជាមុស្លីមល្អដើម្បីបាននៅក្នុងឋានសួគ៌ មិននៅក្នុងឋាននរកជាមួយស្ហៃតនلعنه اللهទេ ។

# លំហាត់ ១

ចូរគូសខ្វែងជើងក្អែកលើរូបនរកខាងក្រោមនេះ ដែលសៃشតطន لعن الله នឹងចូលទៅក្នុងនោះ ។ អ្នកនឹងមិនចូលនរកទេ ព្រោះអ្នកស្តាប់អល់ឡោះហ្វ៍ عز وجل ។



នរក

អ្នកនឹងបានចូលឋានសួគ៌ព្រោះអ្នកស្តាប់អល់ឡោះហ្វ៍ عز وجل ។ ចូរគូរអ្វីដែលអ្នកចង់បាននៅក្នុងឋានសួគ៌ ពេលអ្នកបានចូលឋានសួគ៌ ។

## មេរៀនទី ២

# ព្រះសាស្តាមូហាំម៉ាដ់ អាល់-មុស្ទត៏ហ្វាﷺ

ព្រះសាស្តាមូហាំម៉ាដ់ﷺជាមនុស្សល្អណាស់ ព្រះអង្គﷺមិនដែលក្រោធឡើយទោះបីគេជេរប្រមាថបៀតបៀនព្រះអង្គﷺក៏ដោយ ។

ស្ត្រីចំណាស់ម្នាក់បានប្រព្រឹត្តអំពើកំណាចដាក់ព្រះសាស្តាﷺ ដោយចោលសម្រាមមកលើព្រះអង្គﷺរាល់គ្រាដែលព្រះអង្គﷺដើរកាត់មុខផ្ទះគាត់ ។

ព្រះសាស្តាមូហាំម៉ាដ់ﷺដើរកាត់មុខផ្ទះគាត់រាល់ព្រឹក ទៅឯម៉ាស់ឃ្ជីដ្ ។ រៀងរាល់ព្រឹកស្ត្រីចំណាស់នេះចោលសម្រាមមកលើព្រះអង្គﷺ តែព្រះអង្គﷺមិនដែលក្រេវក្រោធម្តងណាទេ ។

ថ្ងៃមួយ ពេលព្រះសាស្តាﷺដើរកាត់មុខផ្ទះស្ត្រីចំណាស់នេះៗនោះមិនចោលសម្រាមទេ ។ ព្រះសាស្តាﷺផ្អាកដំណើរ សួរស្ត្រីអ្នកជិតផ្ទះថាតើស្ត្រីចំណាស់នោះកើតអ្វីទេ ដ្បិតមិនឃើញគាត់ចោលសម្រាមមកលើព្រះអង្គﷺ ។

ស្ត្រីជិតផ្ទះបានប្រាប់ព្រះអង្គﷺថាស្ត្រីចំណាស់នោះមិនស្រួលខ្លួន កំពុងដេកឈឺនៅលើគ្រែ ។ ព្រះសាស្តាﷺក៏ប្រញាប់ទៅរកស្ត្រីចំណាស់ ព្រោះវាជាប្រការល្អប្រសើរដែលទៅសួរសុខទុក្ខអ្នកជម្ងឺ ដើម្បីសាកសួរក្រែងលោអាចជួយគាត់បានដោយប្រការណាមួយ ។

ពេលជីដូននោះឃើញព្រះសាស្តាﷺ គាត់គិតថាព្រះអង្គﷺមកស្តីបន្ទោសគាត់ឲ្យឃើញសខ្មៅតែម្តង គាត់ក៏បានថា៖ "ហេតុអ្វីចាំឲ្យខ្ញុំឈឺទើបមកស្តីបន្ទោសខ្ញុំ ? ហេតុអ្វីមិនស្តីឲ្យខ្ញុំពេលខ្ញុំមិនឈឺ កាលនៅមានកម្លាំងមាំទាំ ?"

ព្រះសាស្តាមូហាំម៉ាដ់ﷺមានព្រះវចនៈថា ព្រះអង្គﷺមិនមកដើម្បីឈ្លោះជាមួយគាត់ទេ តែព្រះអង្គﷺមកនេះព្រោះតែចង់ជួយមើលគាត់ព្រោះគាត់មិនស្រួលខ្លួន ពីព្រោះអល់ឡោះហ៍ﷻចង់ឲ្យយើងមើលថែរក្សាអ្នកណាដែលឈឺថ្កាត់ ។

ជីដូនភ្ញាក់ផ្អើលណាស់ ដែលឃើញព្រះសាស្តាﷺប្រព្រឹត្តល្អប្រពៃដូច្នេះ ទោះបីគាត់បានប្រព្រឹត្តមិនគប្បីចំពោះព្រះអង្គﷺក៏ដោយនោះ ។

ស្ត្រីចំណាស់រូបនេះក៏បានសម្រេចចិត្តស្តាប់ព្រះសាស្តា ﷺ ហើយប្រព្រឹត្តខ្លួនជានារីមុស្លីមមួយរូប ។

**លំហាត់ ២ក**

# ព្រះសាស្តាមូហាំម៉ាដ់ អាល់-មុស្ទត៏ហ្វាﷺ

ព្រះសាស្តាមូហាំម៉ាដ់ﷺប្រសូតនៅឯ ម៉ាក់កាស់, ថ្ងៃសុក្រ ទី ១៧ ខែ រ៉ប៊ីអ៊ុល អាវ៉ាល់ ឆ្នាំដំរី (عَامُ الْفِيلِ) ។ ព្រះអង្គﷺសោយព្រះទិវង្គតនៅឯម៉ាឌីណាស់ ថ្ងៃទី ២៨ ខែ ស្វហ្វារ ឆ្នាំ ១១ សករាជហ៊ីច្រ៉េះត៏ (គឺក្រោយពីបានភៀសខ្លួនទៅកាន់ម៉ាឌីណាស់)។ ជីទួតព្រះអង្គﷺឈ្មោះ ហាស៊ីម ។ ជីតាព្រះអង្គﷺឈ្មោះ អាប់ឌុល-មុត្តត៏លិប ។ បិតាព្រះអង្គﷺឈ្មោះ អាប់ឌុលឡោះហ៍ ។ មាតាព្រះអង្គﷺឈ្មោះ អាមីណាស់ ។ ព្រះមហេសីរបស់ព្រះសាស្តាមូហាំម៉ាដ់ អាល់-មុស្ទត៏ហ្វាﷺឈ្មោះ ខ៊ុឌីយ៉ាស់عليها السلام ។ ព្រះរាជបុត្រីរបស់ព្រះសាស្តា មូហាំម៉ាដ់ អាល់-មុស្ទត៏ហ្វាﷺឈ្មោះ ហ្វាទីម៉ាស់عليها السلام ។



# លំហាត់ ២៥

ចូរនិយាយរឿងព្រះសាស្ដាមូហាំម៉ាដ់ﷺនិងជីដូនឲ្យឪពុកម្ដាយអ្នកស្ដាប់ ។

ព្រះសាស្ដាមូហាំម៉ាដ់ﷺបានបង្ហាត់បង្រៀនយើងថា៖

១) ឲ្យធ្វើល្អចំពោះអ្នកដទៃទោះបីអ្នកនោះធ្វើអាក្រក់ដាក់យើងក៏ដោយ ។



២) ឲ្យយើងទៅលេងអ្នកជម្ងឺនិងជួយមើលថែរក្សាអ្នកជម្ងឺ ។



**មេរៀនទី ៣**

# ប៊ីប៊ី ហ្វាទិម៉ាស់ អាស់សាហ្ស់រ៉អ៊ុ ﷳ

ប៊ីប៊ី ហ្វាទិម៉ាស់ អាស់សាហ្ស់រ៉អ៊ុ ﷳ (فَاطِمَة الزَّهْرَاء) ធ្វើការធ្ងន់នៅផ្ទះ ។ ព្រះសាស្តា មូហាំម៉ាដ់ ﷺ ព្រះបិតាព្រះនាង ﷳ ឃើញព្រះនាង ﷳ ធ្វើការធ្ងន់ ។

ថ្ងៃមួយព្រះអង្គ ﷺ បានប្រទានអំណោយមួយឲ្យព្រះនាង ﷳ ដែលមានតម្លៃលើសស្រីជំនួយការផ្ទះឬលើសអ្វីៗក្នុងលោកទៅទៀត ។

តើអ្នកដឹងទេថាអំណោយនោះគឺអ្វី ?

ព្រះអង្គ ﷺ បានប្រទានឲ្យព្រះនាង ﷳ នូវ តាស់ប៊ិះហ្ (تَسْبِيح) ។ ព្រះអង្គ ﷺ បានប្រាប់ព្រះនាង ﷳ ថាក្រោយពីបានស្ហ៍ឡាត្ហ៍រួចឲ្យសូត្រថាៈ

-អល់ឡ៉ហ្ហូ អាក់បារ (اَللَّهُ أَكْبَرُ) ៣៤ ដង ។

-អាល់-ហ៊ាំឌុលិលឡាស់ (اَلْحَمْدُ لِلَّهِ) ៣៣ ដង ។

-ស៊ុបហាណល់ឡោះហ៍ (سُبْحَانَ اَللَّهِ) ៣៣ ដង ។

យើងហៅតាស់ប៊ិះហ្នេះថា តាស់ប៊ិះហ្ ប៊ីប៊ី ហ្វាទិម៉ាស់ អាស់សាហ្ស់រ៉អ៊ុ ﷳ ។

ស្ហ៍ឡាត្ហ៍យើងជាផ្កាស្រស់ស្អាតមួយទង ឯតាស់ប៊ិះហ្ ប៊ីប៊ី ហ្វាទិម៉ាស់ ﷳ ជាក្លិនក្រអូបរបស់ស្ហ៍ឡាត្ហ៍នេះ ។

ដូច្នេះហើយបានជាយើងត្រូវសូត្រតាស់ប៊ិះហ្ ប៊ីប៊ី ហ្វាទិម៉ាស់ អាស់សាហ្ស់រ៉អ៊ុ ﷳ ព្រោះយើងចង់ឲ្យស្ហ៍ឡាត្ហ៍យើងក្រអូបដូចផ្កាស្រស់ស្អាតមួយទងដែលក្រអូបដែរ ។

## លំហាត់ ៣ក

ព្រះនាង ហ្វាទីម៉ាស់ អាស់សាស់រ៉អ៊ុ سلام الله عليها ប្រសូតនៅឯម៉ាក់កាស់ ថ្ងៃសុក្រទី ២០ ខែ យូម៉ាដា អាល់-អាឃ្ហីរ៉ោះត៍ (جُمَادَى الآخِرَة) ៨ ឆ្នាំមុនសករាជហ៊ីជ្រ៉ោះត៍ ។ ព្រះនាងសោយទិវង្គតនៅម៉ាឌីណាស់ ថ្ងៃទី ៣ ខែ យូម៉ាដា អាល់-អាឃ្ហីរ៉ោះត៍ ឆ្នាំ ១១ សករាជហ៊ីជ្រ៉ោះត៍ ។



## លំហាត់ ៣៦

ចូរផាត់ពណ៌គ្រាប់តាស់ប៊ិះហ្ម៉ាដោយថាៈ
៣៤ ដង អល់ឡ៉ហ្វូ អាក់បារ (اَللّٰهُ أَكْبَرُ) ។
៣៣ ដង អាល់-ហ៉ាំឌូលិលឡាហ្ស៍ (اَلْحَمْدُ لِلّٰهِ) ។
៣៣ ដង ស៊ុបហ្ហាណាល់ឡោះហ្វ៍ (سُبْحَانَ اَللّٰهِ) ។



## មេរៀនទី ៤

# អ៊ីម៉ាំអាលី صلوات الله عليه والسلام

ថ្ងៃមួយសែយីដ្ហាស៍ ហ្វាទីម៉ាស៍ ប៊ិនទី អាសាដ៍ (فَاطِمَةَ بِنْتَ أَسَدٍ មាតារបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام) បានទៅកាក់បាស៍ដើម្បីបួងសួងអល់ឡោះហ៍ عز وجل សូមឲ្យកូនព្រះនាងដែលនឹងកើតមកនោះមានសុខភាពល្អ ។

ព្រះនាងកំពុងឈរបួងសួងអល់ឡោះហ៍ عز وجل ក្បែរជញ្ជាំងកាក់បាស៍ ស្រាប់តែជញ្ជាំងកាក់បាស៍ប្រេះ ។ ជញ្ជាំងកាក់បាស៍នោះញែកកាន់តែធំអាចដើរចូលបាន ។ ព្រះនាង ហ្វាទីម៉ាស៍ ប៊ិនទី អាសាដ៍ ក៏បានចូលទៅក្នុងកាក់បាស៍តាមប្រលោះនោះ ។ លុះបានចូលទៅដល់ខាងក្នុងហើយប្រលោះនោះបិទជិតវិញ ។ ស្នាមប្រេះនេះនៅតែមានរហូតមកដល់សព្វថ្ងៃនេះ ។

មនុស្សដែលនៅជុំវិញកាក់បាស៍បានឃើញព្រឹត្តិការណ៍នេះ បាននិយាយប្រាប់គ្នាអ្វីដែលខ្លួនបានឃើញ ។ មនុស្សម្នាចង់ដឹងថាតើមានអ្វីកើតឡើងនៅក្នុងកាក់បាស៍ បានយកកូនសោកាក់បាស៍ទៅចាក់បើកទ្វារ ។ គេព្យាយាមចាក់កូនសោបើកទ្វារកាក់បាស៍តែបើកមិនរួច ទ្វារនៅតែបិទជិត ។

កាលព្រឹត្តិការណ៍នេះបានកើតឡើង ព្រះសាស្តាមូហាំម៉ាដ៍ صلى الله عليه وآله وسلم កំពុងតែធ្វើដំណើរ ។ ពេលព្រះអង្គ صلى الله عليه وآله وسلم ត្រឡប់មកវិញ ព្រះអង្គ صلى الله عليه وآله وسلم ទៅម៉ាក់កាស៍ ទ្វារកាក់បាស៍ក៏បានបើកដោយខ្លួនឯង ព្រះនាង ហ្វាទីម៉ាស៍ ប៊ិនទី អាសាដ៍ ចេញមកវិញដោយបីទារក ។ ទារកនោះគឺអ៊ីម៉ាំអាលី صلوات الله عليه والسلام ។

ពេលព្រះសាស្តាមូហាំម៉ាដ៍ صلى الله عليه وآله وسلم បីអ៊ីម៉ាំអាលី صلوات الله عليه والسلام ទើបអ៊ីម៉ាំអាលី صلوات الله عليه والسلام បើកភ្នែកគ្រាដំបូងបង្អស់ ។ ដូច្នេះ អ្វីដែលអ៊ីម៉ាំអាលី صلوات الله عليه والسلام បានឃើញមុនគេគឺព្រះភ័ក្ត្រព្រះសាស្តាមូហាំម៉ាដ៍ صلى الله عليه وآله وسلم ។

មានតែអ៊ីម៉ាំអាលី صلوات الله عليه والسلام មួយគត់ ដែលប្រសូតនៅក្នុងព្រះមហាគ្រឹះអល់ឡោះហ៍ عز وجل ។

## លំហាត់ ៤ក

# អ៊ីមុាំអុាលី صلوات الله عليه والسلام

អ៊ីមុាំអុាលី صلوات الله عليه والسلام ប្រសូតនៅឯមាក់កាស្ង៉ ថ្ងៃទី ១៣ ខែ រ៉យ៉ាប់ ២៣ ឆ្នាំមុនសករាជហ៊ីជ្រ៉េះត៍ ។ ព្រះអង្គ صلوات الله عليه والسلام សោយទិវង្គតនៅគូហ្វាស៍ ថ្ងៃទី ២១ ខែ រ៉ម៉ាដូន ឆ្នាំ ៤០ សករាជហ៊ីជ្រ៉េះត៍ ។



## លំហាត់ ៤ខ

ចូរនិយាយរឿងអ៊ីមុាំអាលី صلوات الله عليه والسلام ឲ្យឪពុកម្តាយអ្នកស្តាប់ ហើយផាត់ពណ៌កាក់បាស់ ។



## មេរៀនទី ៥

# អ៊ីម៉ាំហាសាន់ صلوات الله عليه والسلام

ថ្ងៃមួយ អ៊ីម៉ាំទី ២ របស់យើង គឺអ៊ីម៉ាំ ហាសាន់ صلوات الله عليه والسلام កំពុងសោយ មានឆ្កែមួយដើរចូលមកឈប់ពីមុខព្រះអង្គ صلوات الله عليه والسلام មើលព្រះអង្គ صلوات الله عليه والسلام សោយដូចជាឃ្លានណាស់ ។

អ៊ីម៉ាំ ហាសាន់ صلوات الله عليه والسلام ដួសចំណីព្រះអង្គ صلوات الله عليه والسلام ឲ្យឆ្កែនោះស៊ី ។ ឆ្កែត្របាក់ចំណីនោះ ហើយនៅតែសម្លឹងមើលអ៊ីម៉ាំ صلوات الله عليه والسلام ។ អ៊ីម៉ាំ صلوات الله عليه والسلام ដួសចំណីឲ្យវាស៊ីទៀត ។

បុរសម្នាក់ដែលបានដើរកាត់តាមនោះបានដេញឆ្កែចេញ កុំឲ្យវារំខានអ៊ីម៉ាំ صلوات الله عليه والسلام ដែលកំពុងសោយ ។

អ៊ីម៉ាំ صلوات الله عليه والسلام បានប្រាប់បុរសនោះកុំឲ្យដេញឆ្កែ ព្រោះអល់ឡោះហ៊ូ عز وجل បានបង្កើតវាដូចព្រះអង្គ عز وجل បានបង្កើតយើងរាល់គ្នាដែរ ។ អល់ឡោះហ៊ូ عز وجل ស្រឡាញ់ទាំងសត្វទាំងមនុស្ស ។

ឧត្តមគតិរឿងនេះគឺ ត្រូវធ្វើល្អចំពោះសត្វដែលអល់ឡោះហ៊ូ عز وجل បានបង្កើតមក ។ អល់ឡោះហ៊ូ عز وجل ស្រឡាញ់ទាំងសត្វទាំងមនុស្ស មិនរើសអើងទេ ។

## លំហាត់ ៥ក

អ៊ីម៉ាំ ហាសាន់ صلوات الله عليه والسلام ប្រសូតនៅឯម៉ាឌីណាស់ ថ្ងៃទី ១៥ ខែរ៉ម៉ាដន ឆ្នាំ ៣ សករាជហ៊ីជរ៉ោះត៍ ។ ព្រះអង្គ صلوات الله عليه والسلام សោយទិវង្គតនៅម៉ាឌីណាស់ ថ្ងៃទី ៧ ខែស៍ហ្វារ ឆ្នាំ ៥០ សករាជហ៊ីជរ៉ោះត៍ ។



## លំហាត់ ៥ខ

ចូរនិយាយរឿងអ៊ីម៉ាំហ្ហាសាន់ صلوات الله عليه والسلام និងឆ្កែឃ្លានឲ្យឪពុកម្ដាយអ្នកស្ដាប់ ។



ចូរគូររូបសត្វដែលអ្នកបានជួបរាល់ថ្ងៃ ដែលអ្នកអាចធ្វើល្អចំពោះវា ។

## មេរៀនទី ៦

# អ៊ីម៉ាំហ៊ូសែន صلوات الله عليه والسلام

កាលអ៊ីម៉ាំទី ៣ របស់យើង គឺអ៊ីម៉ាំហ៊ូសែន صلوات الله عليه والسلام បានប្រសូតមក អល់ឡោះហ៍ عزّ وجلّ បានចាត់បញ្ជូនទេវយ្ជីបរ៉អ៊ីល عليه السلام មកសម្តែងការអបអរសាទរចំពោះព្រះរាជវង្ស ។

ពេលយ្ជីបរ៉អ៊ីល عليه السلام ចុះមកកាន់ផែនដី ព្រះអង្គ عليه السلام បានធ្វើដំណើរកាត់តាមកោះមួយ ។ អល់ឡោះហ៍ عزّ وجلّ បានទម្លាក់ទេវតាមួយអង្គឈ្មោះហ្វិត្ត្រុស (فُطْرُس) មកលើកោះនេះព្រោះទេវតានេះមានកំហុស ។ អល់ឡោះហ៍ عزّ وجلّ បានដកស្លាបហ្វិត្ត្រុស ។ លុះហ្វិត្ត្រុសបានឃើញយ្ជីបរ៉អ៊ីល عليه السلام ព្រះអង្គបានសួរថាតើយ្ជីបរ៉អ៊ីល عليه السلام ទៅណា ។ យ្ជីបរ៉អ៊ីល عليه السلام បានតបថាព្រះអង្គ عليه السلام ទៅថ្លែងការអបអរសាទរចំពោះព្រះសាស្តា صلى الله عليه وآله وسلم និងព្រះរាជវង្សព្រះអង្គ صلى الله عليه وآله وسلم ក្នុងឱកាសថ្ងៃប្រសូតអ៊ីម៉ាំហ៊ូសែន صلوات الله عليه والسلام ។

ហ្វិត្ត្រុសបានសូមតាមយ្ជីបរ៉អ៊ីល عليه السلام ទៅផង ។ យ្ជីបរ៉អ៊ីល عليه السلام យល់ព្រមដោយការអនុញ្ញាតរបស់អល់ឡោះហ៍ عزّ وجلّ ។ ទេវតាទាំងពីរក៏បានធ្វើដំណើរទៅរកអ៊ីម៉ាំហ៊ូសែន صلوات الله عليه والسلام ។

មកដល់លំនៅដ្ឋានព្រះសាស្តា صلى الله عليه وآله وسلم ទេវតាទាំងពីរបានសម្តែងការអបអរសាទរចំពោះព្រះសាស្តា صلى الله عليه وآله وسلم និងព្រះរាជកុលដ្ឋាន عليهم السلام ព្រះអង្គ صلى الله عليه وآله وسلم ។ បន្ទាប់មកព្រះសាស្តា صلى الله عليه وآله وسلم បានប្រាប់ហ្វិត្ត្រុសឲ្យទៅមើលអ៊ីម៉ាំហ៊ូសែន صلوات الله عليه والسلام ។

ពេលហ្វិត្ត្រុសប៉ះគ្រែ (ឬអង្រឹង) អ៊ីម៉ាំហ៊ូសែន صلوات الله عليه والسلام ភ្លាម ស្លាបហ្វិត្ត្រុសបានដុះវិញ ។

អល់ឡោះហ៍ عزّ وجلّ បានលើកទោសឲ្យហ្វិត្ត្រុស ព្រះអង្គ عزّ وجلّ បានព្រះរាជទានស្លាបឲ្យហ្វិត្ត្រុសវិញព្រោះហ្វិត្ត្រុសប៉ងប្រាថ្នាចង់បានស្លាបវិញនៅឯគ្រែ (ឬអង្រឹង) អ៊ីម៉ាំហ៊ូសែន صلوات الله عليه والسلام ។

ឧត្តមគតិរឿងនេះគឺ ពេលអ្នកប្រាថ្នាចង់បានអ្វី អ្នកគប្បីយកអ៊ីម៉ាំ عليهم السلام យើងជា

អ្នកកណ្ដាល (គឺអ្នកជួយធ្វើអន្តរាគមន៍) ព្រោះអ៊ីមុាំ عليه السلام យើងជាអ្នកជំនិតរបស់អល់ឡោះហ្ ﷻ ជាងខ្លួនយើងទៅទៀត ។

# លំហាត់ ៦ក

អ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام ប្រសូតនៅឯម៉ាឌីណាស្ហ៍ ថ្ងៃទី ៣ ខែ ស្ហាក់បាន ឆ្នាំ ៤ សករាជហ៊ីជ្រ៉ោះត៍ ។ ព្រះអង្គ صلوات الله عليه والسلام សោយទិវង្គតនៅនគរការបាឡាអ៊ ថ្ងៃទី ១០ ខែ មូហារ៉ម ឆ្នាំ ៦១ សករាជហ៊ីជ្រ៉ោះត៍ ។



## លំហាត់ ៦ខ

ចូរនិយាយឲ្យឪពុកម្ដាយស្ដាប់នូវរឿងទេវតាហ្វិត្នុរុសបានស្លាបវិញ ហើយចូរផាត់ពណ៌រូបខាងក្រោមនេះ ។



## មេរៀនទី ៧

# អ៊ីម៉ាំ អុាលី សៃុនុល-អុាប៊ីឌីន صلوات الله عليه والسلام

អ៊ីម៉ាំទី ៤ របស់យើង គឺអ៊ីម៉ាំ អុាលី សៃុនុល-អុាប៊ីឌីន صلوات الله عليه والسلام ជាបុគ្គលល្អប្រសើរ និងមានអំណត់អត់ធ្មត់ណាស់ ។ ព្រះអង្គ صلوات الله عليه والسلام មិនដែលក្រេវក្រោធឡើយ ព្រះអង្គ صلوات الله عليه والسلام រក្សាអាការញញឹមរម្យទមជានិច្ច ។

ថ្ងៃមួយ អ៊ីម៉ាំ អុាលី សៃុនុល-អុាប៊ីឌីន صلوات الله عليه والسلام កំពុងដើរជាមួយមិត្តពីរបីនាក់ ព្រះអង្គ صلوات الله عليه والسلام បានឃើញបុរសចំណាស់ម្នាក់លីកញ្ចប់ធំធ្ងន់មួយ ឯកូនប្រុសគាត់ដើរក្បែរគាត់ ។

អ៊ីម៉ាំ អុាលី សៃុនុល-អុាប៊ីឌីន صلوات الله عليه والسلام បាត់បង់អាការញញឹមញញែម ទៅជាក្រេវក្រោធ ។ មិត្តព្រះអង្គ صلوات الله عليه والسلام ភ្ញាក់ផ្អើលដោយបានឃើញអ៊ីម៉ាំ صلوات الله عليه والسلام នៅក្នុងសភាពនេះ ព្រោះតែមិនដែលឃើញព្រះអង្គ صلوات الله عليه والسلام ទោសៈឡើយ ។

ពួកគេក៏បានសួរព្រះអង្គ صلوات الله عليه والسلام អំពីមូលហេតុ ដែលធ្វើឲ្យព្រះអង្គ صلوات الله عليه والسلام ទោសៈបែបនេះ ។ អ៊ីម៉ាំ صلوات الله عليه والسلام បានតបថា ឃើញកូនប្រុសដើរក្បែរឪពុក មិនជួយឪពុក ទុកឲ្យឪពុកលីរែកបន្ទុកធ្ងន់នោះធ្វើឲ្យព្រះអង្គ صلوات الله عليه والسلام ក្រោធជាទីបំផុត ។

ឧត្តមគតិរឿងនេះគឺ ត្រូវជួយឪពុកម្ដាយជានិច្ច ទោះបីលោកមិនហៅឲ្យជួយក៏ដោយ (ឧទាហរណ៍ អ្នកអាចរៀបរបស់លេងទុកឲ្យមានរបៀបរៀបរយពេលអ្នកលេងរួច ។)

# លំហាត់ ៧ក

អ៊ីម៉ាំ អ្ទាលី ស្ជែនុល-អ្ទាប៊ីឌីន صلوات الله عليه والسلام ប្រសូតនៅឯម៉ាឌីណាស់ ថ្ងៃទី ៥ ខែស្ហាក់បាន ឆ្នាំ ៣៨ សករាជហ៊ីជ្ជរ៉ោះត៍ ។ ព្រះអង្គ صلوات الله عليه والسلام សោយទិវង្គតនៅម៉ាឌីណាស់ ថ្ងៃទី ២៥ មូហារ៉ម ឆ្នាំ ៩៥ សករាជហ៊ីជ្ជរ៉ោះត៍ ។

ព្រះបិតា ៖
អ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام

មាតា ៖
ប៊ីប៊ី ស្ហាស្សរ៉បានូ (شَهْرَبَانُو)

**អ៊ីម៉ាំ អ្ទាលី ស្ជែនុល-អ្ទាប៊ីឌីន صلوات الله عليه والسلام**

ព្រះរាជបុត្រ ៖
អ៊ីម៉ាំ មូហាំម៉ាដ់ អាល់-បាគៀរ صلوات الله عليه والسلام

# លំហាត់ ៧ខ

ចូរអ្នកនិយាយរឿងអ៊ីម៉ាំទីបួនរបស់យើងក្រោចឲ្យឪពុកម្ដាយអ្នកស្ដាប់ ។



ចូរផាត់ពណ៌រូបបុរសទ្រូបន្ទុកធ្ងន់ ។ រួចហើយចូរគូរកិច្ចការនីមួយដែលអ្នកអាចជួយធ្វើឪពុកម្ដាយអ្នកបាននៅឯផ្ទះ ។

## មេរៀនទី ៨

# អ៊ីមុាំ មូហ៊ាំម៉ាដ់ អាល់-បាកៀ្វរ صلوات الله عليه والسلام

សម័យអ៊ីមុាំទី ៥ របស់យើង គឺអ៊ីមុាំ មូហ៊ាំម៉ាដ់ អាល់-បាកៀ្វរ صلوات الله عليه والسلام មុស្លីមប្រើកាក់ប្រាក់របស់ពួករូម ។ ស្តេចរូមបានសម្រេចបោះពុម្ភកាក់ប្រាក់ថ្មីដោយមានចារនូវពាក្យប្រមាថសាសនាអ៊ីស្លាម ។

ស្តេចវ៉ាលីដ្ធដែលជាមុស្លីមនោះមិនដឹងត្រូវធ្វើយ៉ាងណាទេ ។ គេត្រូវការកាក់ប្រាក់ តែក៏មិនចង់ប្រើកាក់ប្រាក់ដែលជិតជាប់នូវប្រការប្រមាថសាសនាអ៊ីស្លាមទេ ។

ស្តេចវ៉ាលីដ្ធបានសម្រេចចិត្តសូមយោបល់ពីអ៊ីមុាំទី ៥ របស់យើង គឺអ៊ីមុាំ មូហ៊ាំម៉ាដ់ អាល់-បាកៀ្វរ صلوات الله عليه والسلام ថាតើត្រូវធ្វើយ៉ាងណា ។ អ៊ីមុាំ صلوات الله عليه والسلام បានប្រាប់ស្តេចវ៉ាលីដ្ធថាឲ្យបោះពុម្ភកាក់ប្រាក់ថ្មីដែរឲ្យមុស្លីមប្រើប្រាស់អំណឺះតទៅ ។

អ៊ីមុាំ មូហ៊ាំម៉ាដ់ អាល់-បាកៀ្វរ صلوات الله عليه والسلام បានប្រាប់ស្តេចវ៉ាលីដ្ធថាឲ្យធ្វើកាក់ប្រាក់ដោយចារនៅលើមុខម្ខាងថា៖ "لَا إِلَهَ إِلَّا اَللَّهُ ឡា អ៊ីឡាហា អ៊ីលឡុលឡោះហ្ម៍" លើមុខកាក់ម្ខាងទៀតឲ្យចារថា៖ "مُحَمَّدٌ رَسُولُ اَللَّهِ មូហ៊ាំម៉ាដ់ រ៉ស៊ូលុលឡោះហ្ម៍" ។

ស្តេចវ៉ាលីដ្ធយល់ឃើញថានេះគឺយោបល់ល្អណាស់ កាក់ប្រាក់ក៏ត្រូវបានបង្កើតឡើងដូចនេះឯង ។

ឧត្តមគតិរឿងនេះគឺ យើងត្រូវចេះដឹងអ្វីៗដែលអ៊ីមុាំយើងបានបង្ហាត់បង្រៀនយើង ។ អ៊ីមុាំ عليهم السلام យើងដឹងជានិច្ចថាត្រូវធ្វើម្តេចខ្លះ ។

## លំហាត់ ៨ក

អ៊ីម៉ាំ មូហាំម៉ាដ់ អាល់-បាគៀរ صلوات الله عليه والسلام ប្រសូតនៅឯម៉ាឌីណាស់ ថ្ងៃទី ១ ខែ រ៉យ៉ាប់ ឆ្នាំ ៥៧ សករាជហ៊ីជ្រ៉ោះត៏ ។ ព្រះអង្គ صلوات الله عليه والسلام សោយទិវង្គតនៅម៉ាឌីណាស់ ថ្ងៃទី ៧ ខែ ស៊ុលហ៊ីជ្ជយ៉ាស់ ឆ្នាំ ១១៤ សករាជហ៊ីជ្រ៉ោះត៏ ។

ព្រះបិតា ៖
អ៊ីម៉ាំ អ៊ុាលី ស្សែនុល-អ៊ុាប៊ីឌីន صلوات الله عليه والسلام

មាតា ៖
ប៊ីប៊ី ហ្វាទីម៉ាស់ ប៊ិនទី អាល់-ហ៊ាសាន់

**អ៊ីម៉ាំ មូហាំម៉ាដ់ អាល់-បាគៀរ صلوات الله عليه والسلام**

ព្រះរាជបុត្រ ៖
អ៊ីម៉ាំ យ៉ាក៊ុំហ្វារ អាស្ស-ស្សឌិក صلوات الله عليه والسلام

## លំហាត់ ៨២

ចូរអ្នកនិយាយរឿង អ៊ីមុាំ មូហ៊ាំម៉ាដ់ អាល់-បាគៀ្យរ صلوات الله عليه والسلام និងកាក់ប្រាក់ឲ្យឪពុកម្ដាយអ្នកស្ដាប់ ហើយផាត់ពណ៌កាក់ប្រាក់។ ចូរសាកល្បងគូររូបកាក់ប្រាក់ក្នុងសម័យអ៊ីមុាំទី ៥ ។



## មេរៀនទី ៩

# អ៊ីម៉ាំ យ៉ាក្កហ្វារ អាស្ស-ស្វឌិក្កសلوات الله عليه والسلام

ថ្ងៃមួយ អ៊ីម៉ាំទី ៦ របស់យើង គឺអ៊ីម៉ាំ យ៉ាក្កហ្វារ អាស្ស-ស្វឌិក្ក صلوات الله عليه والسلام ដើរតាមផ្លូវ ឃើញគេចោលចំណីដែលសល់ពីបរិភោគលើផ្លូវដើរ ។

អ៊ីម៉ាំ យ៉ាក្កហ្វារ អាស្ស-ស្វឌិក្ក صلوات الله عليه والسلام តូចចិត្តណាស់ពេលឃើញបែបនេះ ។ ព្រះអង្គ صلوات الله عليه والسلام បានពន្យល់ប្រាប់ពួកនោះថាធ្វើបែបនេះមិនត្រឹមត្រូវទេ ព្រោះមានមនុស្សច្រើនទៀតក្នុងលោកដែលអត់បាយ ។

ព្រះសាស្តា صلى الله عليه وآله وسلم យើង ព្រះសាស្តាមូហាំម៉ាដ្ឋ صلى الله عليه وآله وسلم មានព្រះវចនៈថាបើអ្នកមិនគិតដល់មុស្លីមទ័លក្រទេ អ្នកមិនមែនមុស្លីមទេ ។

ដូច្នេះហើយបានជាអ៊ីម៉ាំ صلوات الله عليه والسلام យើងធ្លាប់តែយកចំណីអាហារ ទៅចែកឲ្យជនក្រីក្រក្នុងពេលយប់ងងឹតទោះបីធាតុអាកាសត្រជាក់ក៏ដោយ ។

ឧត្តមគតិរឿងនេះគឺ កុំលោភចង់បានលើសពីសេចក្តីត្រូវការ ត្រូវគិតដល់អ្នកដទៃ ជាពិសេសដល់មុស្លីម ដែលមិនមានគ្រប់សព្វដូចអ្នកដែរនោះ ។

**លំហាត់ ៩ក**

# អ៊ីមុាំ យ៉ាក់ហ្វារ អាស្ស-ស្វឌិក្ក صلوات الله عليه والسلام

អ៊ីមុាំ យ៉ាក់ហ្វារ អាស្ស-ស្វឌិក្ក صلوات الله عليه والسلام ប្រសូតនៅឯម៉ាឌីណាស្ស ថ្ងៃទី ១៧ ខែ រ៉ប៊ីអ៊ុល អាវ៉ាល់ ឆ្នាំ ៨៣ សករាជហ៊ិជ្ជរ៉ោះត៍ (ដូចថ្ងៃកំណើតព្រះសាស្ដា صلى الله عليه وآله وسلم យើងដែរ) ។ ព្រះអង្គ صلوات الله عليه والسلام សោយទិវង្គតនៅម៉ាឌីណាស្ស ថ្ងៃទី ២៥ ខែ ស្សៅវ៉ាល់ ឆ្នាំ ១៤៨ សករាជហ៊ិជ្ជរ៉ោះត៍ ។

ព្រះបិតា ៖
អ៊ីមុាំ មូហ៊ាំម៉ាដ់ អាល់-បាក្កៀរ صلوات الله عليه والسلام

មាតា ៖
ប៊ីប៊ី ហ្វាទីម៉ាស្ស (أم فروة بنت القاسم អ៊ុម ហ្វារវ៉ាស្ស)

**អ៊ីមុាំ យ៉ាក់ហ្វារ អាស្ស-ស្វឌិក្ក صلوات الله عليه والسلام**

ព្រះរាជបុត្រ ៖
អ៊ីមុាំ មូសា អាល់-កាស្ឋិម صلوات الله عليه والسلام

## លំហាត់ ៩២

# ចូរអ្នកកុំភ្លេច

ចូរអ្នកកុំភ្លេច

ចូរអ្នកកុំភ្លេច... បងប្អូនមុស្លីមប្រុសស្រីឯទៀតក្នុងលោក ពេលអ្នកបរិភោគ ។



ចូរផាត់ពណ៌រូបគ្រឿងបរិភោគខាងលើនេះ ។

## មេរៀនទី ១០

# អ៊ីមុាំ មូសា អាល់-កាស៊្ទីម صلوات الله عليه والسلام

សម័យអ៊ីមុាំទី ៧ របស់យើង គឺអ៊ីមុាំ មូសា អាល់-កាស៊្ទីម صلوات الله عليه والسلام ស្តេចខ៍លិហ្វកំណាចឈ្មោះ ហារូន ស្អប់អ៊ីមុាំយើងណាស់ ។

ស្តេចហារូនមកកាន់នគរម៉ាឌីណាស់ដែលជាទីលំនៅរបស់អ៊ីមុាំ មូសា អាល់-កាស៊្ទីម صلوات الله عليه والسلام ។ ស្តេចហារូនបានចាប់ខ្លួនអ៊ីមុាំដាក់ពន្ធនាគារនៅឯនគរបាស់ព៉េះត្ថ៍ ។

អ៊ីមុាំ មូសា អាល់-កាស៊្ទីម صلوات الله عليه والسلام នៅក្នុងពន្ធនាគានេះក្រោមការយាមល្បាតរបស់បុរសម្នាក់ឈ្មោះ យ៉ាស៊ុយ៉ា ។

អ៊ីមុាំ មូសា អាល់-កាស៊្ទីម صلوات الله عليه والسلام ជាមនុស្សម្នាក់ដែលប្រកបដោយមិត្តភាព មានវោហារកោសល្យ ពូកែនិយាយស្តីជាមួយមនុស្សទូទៅ សូម្បីតែយ៉ាស៊ុយ៉ាឆ្មាំពន្ធនាគារក៏ព្រះអង្គ صلوات الله عليه والسلام និយាយសាសងរកដែរ ។ មិនយូរប៉ុន្មាន យ៉ាស៊ុយ៉ាមានអារម្មណ៍អល់អែកដែលយាមល្បាតមនុស្សល្អបែបនេះនៅក្នុងពន្ធនាគារ ។

ស្តេចហារូនបានដឹងរឿងនេះក៏បាននាំខ្លួនអ៊ីមុាំ មូសា អាល់-កាស៊្ទីម صلوات الله عليه والسلام ទៅឃុំឃាំងនៅឯពន្ធនាគារមួយទៀត ។ សេចក្តីស្រឡាញ់និងសេចក្តីគោរពចំពោះអ៊ីមុាំ صلوات الله عليه والسلام ក៏បានធ្វើឲ្យឆ្មាំពន្ធនាគារម្នាក់ទៀតនោះខ្លាចក្រែងចិត្តព្រះអង្គ صلوات الله عليه والسلام ទៀតដែរ ។

ទីបំផុតស្តេចហារូនបានឲ្យគេសម្លាប់អ៊ីមុាំ មូសា អាល់-កាស៊្ទីម صلوات الله عليه والسلام ។

ឧត្តមគតិរឿងនេះគឺ ទោះបីបុគ្គលដែលនៅពីមុខអ្នកជាមនុស្សកំណាចយ៉ាងណាក៏ដោយ អ្នកត្រូវតែមានអាកប្បកិរិយាស្លូតបូតជានិច្ច ។ បុគ្គលនោះនឹងខ្លាចក្រែងចិត្តអ្នកដែលបានប្រព្រឹត្តអគប្បីមកលើខ្លួនអ្នក ។

**លំហាត់ ១០ក**

# អ៊ីម៉ាំ មូសា អាល់-កាស៊ីម صلوات الله عليه والسلام

អ៊ីម៉ាំ មូសា អាល់-កាស៊ីម صلوات الله عليه والسلام ប្រសូតនៅឯស្រុកអាប់វ៉ាអ៍ ថ្ងៃទី ៧ ខែ ស្វ៍ហ្វារ ឆ្នាំ ១២៨ សករាជហ្ទ៊ីច្រ៉ះត៍ (ខែស្វ៍ហ្វារជាខែកាន់ទុក្ខ គេធ្វើបុណ្យខួបកំណើតព្រះអង្គ صلوات الله عليه والسلام ថ្ងៃទី ៧ ខែ ៧ ពីព្រោះព្រះអង្គ صلوات الله عليه والسلام ជាអ៊ីម៉ាំទី ៧ របស់យើង)។ ព្រះអង្គ صلوات الله عليه والسلام សោយទិវង្គតនៅឯនគរបាក់ដ្វាដ់ ថ្ងៃទី ២៥ ខែ រ៉យ៉ាប់ ឆ្នាំ ១៨៣ សករាជហ្ទ៊ីច្រ៉ះត៍ ។

ព្រះបិតា ៖
អ៊ីម៉ាំ យ៉ាក់ហ្វារ អាស្វ់-ស្វ៍ឌិក្គ صلوات الله عليه والسلام

មាតា ៖
ប៊ីប៊ី ហ្វាមីដ្វាស់ (حَمِيدَة)

**អ៊ីម៉ាំ មូសា អាល់-កាស៊ីម صلوات الله عليه والسلام**

រាជបុត្រី ៖
ប៊ីប៊ី ហ្វាទីម៉ាស់ អាល់-ម៉ាក់ស៊្វូម៉ាស់
(فاطمة المعصومة)

ព្រះរាជបុត្រ ៖
អ៊ីម៉ាំ អាលី អារ-រីដ្ឋ៍ صلوات الله عليه والسلام

## លំហាត់ ១០ខ

ចូរនិយាយរឿងអ៊ីម៉ាំទី ៧ របស់យើងឲ្យឪពុកម្តាយស្តាប់ កាលគេឃុំឃាំងព្រះអង្គ صلوات الله عليه والسلام កាលអ្នកយាមពន្ធនាគារដឹងខ្លួនថានៅលើផ្លូវខុស ។



## មេរៀនទី ១១

# អ៊ីម៉ាំ អាលី អារ-រីដ៏ صلوات الله عليه والسلام

អ៊ីម៉ាំទី ៨ របស់យើង គឺអ៊ីម៉ាំ អាលី អារ-រីដ៏ صلوات الله عليه والسلام ។ ព្រះអង្គ صلوات الله عليه والسلام មានព្រះនាមមួយទៀតថា អីម៉ាំ ដ៏មីន (الامام الضامن) ។ ដ៏មីនមានន័យសន្តិសុខ ។

ថ្ងៃមួយ អ៊ីម៉ាំ صلوات الله عليه والسلام កំពុងដើរ ព្រះអង្គ صلوات الله عليه والسلام បានជួបអ្នកបាញ់សត្វកំពុងសម្លាប់សត្វប្រើស ។ សត្វប្រើសព្យាយាមរត់គេចខ្លួន ។ ពេលឃើញអ៊ីម៉ាំ صلوات الله عليه والسلام សត្វប្រើសនោះនិយាយជាមួយអ៊ីម៉ាំ صلوات الله عليه والسلام ។

អ៊ីម៉ាំ صلوات الله عليه والسلام បានសូមអ្នកបាញ់សត្វលែងប្រើសឲ្យរួចជីវិត ដើម្បីវានឹងទៅបំបៅកូនវាដែលកំពុងឃ្លាន ។ អ៊ីម៉ាំ صلوات الله عليه والسلام បានប្រាប់អ្នកបាញ់សត្វដែរថាពេលមេប្រើសឲ្យកូនវាបៅរួច វានឹងត្រឡប់មកវិញ ។

អ្នកបាញ់សត្វក៏បានលែងប្រើសតាមសំណូមពរអ៊ីម៉ាំ صلوات الله عليه والسلام តែគាត់មិនជឿទេថាមេប្រើសនឹងត្រឡប់មកវិញ ។ ហេតុដូច្នេះអ៊ីម៉ាំ صلوات الله عليه والسلام បានរង់ចាំជាមួយព្រានបាញ់សត្វនោះដែរលុះត្រាមេប្រើសត្រឡប់មកវិញ ។ មេប្រើសត្រឡប់មកវិញមែនជាមួយកូនវា ហើយបានសូមឲ្យអ៊ីម៉ាំ صلوات الله عليه والسلام ចិញ្ចឹមកូនវាពេលអត់ពីវា ។

ឧត្តមគតិរឿងនេះគឺ អ៊ីម៉ាំ អាលី អារ-រីដ៏ صلوات الله عليه والسلام ជាអ៊ីម៉ាំសន្តិសុខដែលយើងសូមឲ្យថែរក្សាអ្នកណាដែលចង់ធ្វើដំណើរ ។ អ៊ីម៉ាំទាំងអស់ عليهم السلام មិននិយាយកុហកដាច់ខាត ។

**លំហាត់ ១១ក**

# អ៊ីម៉ាំ អាុលី អារ-រីដ៏ صلوات الله عليه والسلام

អ៊ីម៉ាំ អាុលី អារ-រីដ៏ صلوات الله عليه والسلام ប្រសូតនៅឯម៉ាឌីណាស់ ថ្ងៃទី ១១ ខែ ស៊ុលកក្កុំដ្ហាស់ ឆ្នាំ ១៤៨ សករាជហ៊ីជ្រ៉ោះត៍ ។ ព្រះអង្គ صلوات الله عليه والسلام សោយទិវង្គតនៅស្រុកម៉ាស្ហ៊ុហ្ហាដ់ ប្រទេសអ៊ីរ៉ង់ ថ្ងៃទី ២៩ ខែ ស្ហ៍ហ្ហារ ឆ្នាំ ២០៣ សករាជហ៊ីជ្រ៉ោះត៍ ។

ព្រះបិតា ៖
អ៊ីម៉ាំ មូសា អាល់-កាស្ហ៊ីម صلوات الله عليه والسلام

មាតា ៖
ប៊ីប៊ី អុំមុល-បានីន ណាជ្ជ៉ម៉ាស់
(أُمّ الْبَنِين نجمة)

**អ៊ីម៉ាំ អាុលី អារ-រីដ៏ صلوات الله عليه والسلام**

ព្រះរាជបុត្រ ៖
អ៊ីម៉ាំ មូហ៊ាំម៉ាដ់ អាត់-តាគ្គី صلوات الله عليه والسلام

## លំហាត់ ១១ខ

ចូរនិយាយឲ្យឪពុកម្ដាយស្ដាប់រឿងបណ្ដាំមេប្រើសមុនព្រានសម្លាប់វា ។







## មេរៀនទី ១២

# អ៊ីម៉ាំ មូហ៊ាំម៉ាដ់ អាត់-តាគ្គី صلوات الله عليه والسلام

ថ្ងៃមួយ កាលអ៊ីម៉ាំទី ៩ របស់យើង គឺអ៊ីម៉ាំ មូហ៊ាំម៉ាដ់ អាត់-តាគ្គី صلوات الله عليه والسلام នៅក្មេងនៅឡើយ ព្រះអង្គ صلوات الله عليه والسلام បានដើរតាមផ្លូវ ។ ស្តេចខ៊ុលិហ្វ ម៉ាក់មូន និងទាហានចូលមកជិតព្រះអង្គ صلوات الله عليه والسلام ។ ក្មេងៗដែលដើរតាមផ្លូវនោះខ្លាច រត់គេចខ្លួនអស់សល់តែអ៊ីម៉ាំ صلوات الله عليه والسلام យើង ។

ស្តេចម៉ាក់មូនបញ្ឈប់រទេះសេះ សួរអ៊ីម៉ាំ មូហ៊ាំម៉ាដ់ អាត់-តាគ្គី صلوات الله عليه والسلام ថាហេតុអ្វីព្រះអង្គ صلوات الله عليه والسلام មិនរត់ដូចកូនក្មេងឯទៀត ។

អ៊ីម៉ាំ មូហ៊ាំម៉ាដ់ អាត់-តាគ្គី صلوات الله عليه والسلام បានឆ្លើយថាព្រះអង្គ صلوات الله عليه والسلام មិនបានធ្វើអ្វីខុសទេ ឯផ្លូវក៏ធំគួរសមអាចដើរបានពីរនាក់ ។

ស្តេចម៉ាក់មូនសួរអ៊ីម៉ាំ صلوات الله عليه والسلام ថាព្រះអង្គ صلوات الله عليه والسلام ជាអ្នកណា ។ អ៊ីម៉ាំ صلوات الله عليه والسلام ក៏បានប្រាប់ឲ្យស្គាល់ត្រកូលព្រះអង្គ صلوات الله عليه والسلام ។ ស្តេចម៉ាក់មូនបានឲ្យអ៊ីម៉ាំ صلوات الله عليه والسلام ទាយថាតើខ្លួនកាន់អ្វីក្នុងដៃក្តាប់ ។

អ៊ីម៉ាំ មូហ៊ាំម៉ាដ់ អាត់-តាគ្គី صلوات الله عليه والسلام បានដឹងជាមុនស្រេច ដោយមិនបាច់មើល ថាម៉ាក់មូនកាន់កូនត្រីក្នុងដៃ ។

ឧត្តមគតិរឿងនេះគឺ អ៊ីម៉ាំទាំងអស់ عليهم السلام ជាបុគ្គលពិសេសដែលចេះដឹងសព្វគ្រប់ ។ អ្នកមិនត្រូវខ្លាចអ្វីៗទេ មិនត្រូវខ្លាចអ្នកណាទេ ព្រោះអល់ឡោះហ៊្ មعز وجل ទ្រង់ខ្លាំងពូកែ ព្រះអង្គ عز وجل ថែរក្សាអ្នក ។

## លំហាត់ ១២ក

# អ៊ីម៉ាំ មូហ៊ាំម៉ាដ់ អាត់-តាគ៊ី صلوات الله عليه والسلام

អ៊ីម៉ាំ មូហ៊ាំម៉ាដ់ អាត់-តាគ៊ី صلوات الله عليه والسلام ប្រសូតនៅឯម៉ាឌីណាស់ ថ្ងៃទី ១០ ខែ រ៉យ៉ាប់ ឆ្នាំ ១៩៥ សករាជហ៊ីច្ជរ៉ោះត៍ ។ ព្រះអង្គ صلوات الله عليه والسلام សោយទិវង្គតនៅស្រុកកាស្ឋ៊ីម៉ែន៍ (ٱلْكَاظِمَيْن ប្រទេសអ៊ីរ៉ាក់) ថ្ងៃទី ២៩ ខែ ស្ហ៊ុលក្អក៏ដ្ឋាស់ ឆ្នាំ ២២០ សករាជ ហ៊ីច្ជរ៉ោះត៍ ។



## លំហាត់ ១២ខ

ចូរនិយាយប្រាប់ឪពុកម្ដាយរឿងអ៊ីម៉ាំ មូហ៊ាំម៉ាដ់ អាត់-តាគ្គីعليه والسلام صلوات الله ដឹងថាមានអ្វីនៅក្នុងដៃស្ដេចម៉ាក់មូនដោយមិនបាច់មើល ។



## មេរៀនទី ១៣

# អ៊ីម៉ាំ អាលី អាន់-ណាគ្គី صلوات الله عليه والسلام

សម័យអ៊ីម៉ាំទី ១០ របស់យើង គឺអ៊ីម៉ាំ អាលី អាន់-ណាគ្គី صلوات الله عليه والسلام មានស្តេចកំណាចមួយឈ្មោះមូតាវ៉ាក់គីល ។

ថ្ងៃមួយមូតាវ៉ាក់គីលធ្លាក់ខ្លួនឈឺធ្ងន់ ។ មិនមានគ្រូពេទ្យណាអាចព្យាបាលស្តេចនេះជាទេ ។

ម្តាយរបស់មូតាវ៉ាក់គីលពិបាកចិត្តណាស់ គាត់បានសូមឲ្យអ៊ីម៉ាំ អាលី អាន់-ណាគ្គី صلوات الله عليه والسلام ជួយ ។

អ៊ីម៉ាំ អាលី អាន់-ណាគ្គី صلوات الله عليه والسلام បានប្រាប់ឲ្យគាត់យកថ្នាំទៅឲ្យមូតាវ៉ាក់គីលទទួលទានដើម្បីនឹងបានធូរស្រាល ។ គាត់ក៏បានយកថ្នាំដែលអ៊ីម៉ាំ صلوات الله عليه والسلام បានប្រាប់នោះទៅឲ្យកូនគាត់ទទួលទាន មូតាវ៉ាក់គីលក៏បានជាសះស្បើយឡើងវិញ ។

ពួកគ្រូពេទ្យទាំងអស់ស្ងើចណាស់ ។

ទោះបីមូតាវ៉ាក់គីលជាមនុស្សកំណាចក៏ដោយ ក៏អ៊ីម៉ាំ អាលី អាន់-ណាគ្គី صلوات الله عليه والسلام ជួយសង្គ្រោះដែរព្រោះម្តាយស្តេចនេះបានមកសូមឲ្យព្រះអង្គ صلوات الله عليه والسلام ជួយ ។

ឧត្តមគតិរឿងនេះគឺ អ្នកណាក៏ដោយដែលសូមជំនួយពីអ្នក អ្នកត្រូវតែជួយអ្នកនោះ ទោះបីអ្នកនោះនៅលើផ្លូវមិនត្រឹមត្រូវក៏ដោយ ។

**លំហាត់ ១៣ក**

# អ៊ីម៉ាំ អាលី អាន់-ណាគ្គី صلوات الله عليه والسلام

អ៊ីម៉ាំ អាលី អាន់-ណាគ្គី صلوات الله عليه والسلام ប្រសូតនៅឯស្រុកស៊្វរបាស្ង់ (ជិតម៉ាឌីណាស្ង់) ថ្ងៃទី ១៥ ខែ ស៊ុលហ៊ិច្ចយ៉ាស្ង់ ឆ្នាំ ២១២ សករាជហ៊្វិច្ចរ៉ោះត្ហ៍ ។ ព្រះអង្គ صلوات الله عليه والسلام សោយទិវង្គតនៅឯស្រុកសាម៉ារ៉អ៍ (ប្រទេសអ៊ីរ៉ាក់) ថ្ងៃទី ៣ ខែ រ៉យ៉ាប់ ឆ្នាំ ២៥៤ សករាជហ៊្វិច្ចរ៉ោះត្ហ៍ ។



## លំហាត់ ១៣ខ

ចូរនិយាយប្រាប់ឪពុកម្ដាយរឿងអ៊ីមុាំ អាុលី អាន់-ណាគ្វីصلوات الله عليه والسلامព្យាបាលស្ដេចមូតាវ៉ាក់គីលលុះជាសះស្បើយ ។



## មេរៀនទី ១៤

# អ៊ីម៉ាំ ហ្ញាសាន់ អាល់-អ្ញស់ការី صلوات الله عليه والسلام

ពេលអ៊ីម៉ាំទី ១១ របស់យើង គឺអ៊ីម៉ាំ ហ្ញាសាន់ អាល់-អ្ញស់ការី صلوات الله عليه والسلام ប្រសូតមក ទោះបីព្រះអង្គ صلوات الله عليه والسلام ជាទារកក៏ដោយ ដូចអ៊ីម៉ាំទាំងអស់ដែរ ព្រះអង្គ صلوات الله عليه والسلام បានក្រាបប្រណិប័តន៍ (គឺស៊្ញូឃ្ញូដ្ញ) អល់ឡោះហ្ញ៍ عز وجل ភ្លាមដោយប្រកាសប្តេជ្ញាថាមានតែអល់ឡោះហ្ញ៍ عز وجل មួយគត់ជាព្រះ ។

អ៊ីម៉ាំទាំងអស់ عليهم السلام របស់យើងជាមនុស្សលើសពីធម្មតា ។ អាស្រ័យហេតុនេះឯងបានជា ពេលកើតមកស្ទើរតែភ្លាមៗ ព្រះអង្គ عليهم السلام ប្រាប់មនុស្សឲ្យស្គាល់អល់ឡោះហ្ញ៍ عز وجل ឲ្យស្គាល់សារៈសំខាន់ក្នុងការគោរពសក្ការៈអល់ឡោះហ្ញ៍ عز وجل ចំណែកទារកដទៃយំរ៉ាវ៉ា ។

ដូច្នេះហើយបានជាអ៊ីម៉ាំ عليهم السلام អាចទៅជាមេដឹកនាំមុស្លីមទាំងអស់បាន ដោយគ្មានកំណត់អាយុ ។

អ៊ីម៉ាំទាំងអស់ عليهم السلام សុទ្ធតែត្រូវអល់ឡោះហ្ញ៍ عز وجل ជ្រើសរើស ។ ពុំមានអ្នកណាមួយក្រៅពីអល់ឡោះហ្ញ៍ عز وجل អាចតែងតាំងអ្នកណាមួយជាអ៊ីម៉ាំបានទេ ។

អល់ឡោះហ្ញ៍ عز وجل បានជ្រើសរើសអ៊ីម៉ាំ ហ្ញាសាន់ អាល់-អ្ញស់ការី صلوات الله عليه والسلام ជាអ៊ីម៉ាំទី ១១ និងជាបិតារបស់អ៊ីម៉ាំទី ១២ របស់យើង គឺអ៊ីម៉ាំ មូហ្ញាំម៉ាដ្ញ អាល់-ម៉ាស្ញ៉ឌី صلوات الله عليه والسلام អ៊ីម៉ាំរបស់សម័យកាលយើង (គឺអ៊ីម៉ាំរបស់មនុស្សទាំងអស់ក្នុងបច្ចុប្បន្ននេះ) ។

**លំហាត់ ១៤ក**

# អ៊ីម៉ាំ ហាសាន់ អាល់-អាស់ការី صلوات الله عليه والسلام

អ៊ីម៉ាំ ហាសាន់ អាល់-អាស់ការី صلوات الله عليه والسلام ប្រសូតនៅឯម៉ាឌីណាស់ ថ្ងៃទី ១០ ខែ រ៉ប៊ីអ៊ុល អាខៀរ ឆ្នាំ ២៣២ សករាជហ៊ីជរ៉ោះត៏ ។ ព្រះអង្គ صلوات الله عليه والسلام សោយទិវង្គតនៅឯស្រុកសាម៉ារ៉អ៊ុ (ប្រទេសអ៊ីរ៉ាក់) ថ្ងៃទី ៨ ខែ រ៉ប៊ីអ៊ុល អាវ៉ាល់ ឆ្នាំ ២៦០ សករាជហ៊ីជរ៉ោះត៏ ។



# លំហាត់ ១៤ខ

ពេលទារកកើតមក វា ៖



យំ



លេង



បៅ ឬ ដេក

តែពេលអ៊ីម៉ាំ ហុាសាន់ អាល់-អុាសមការី صلوات الله عليه والسلام ប្រសូតមក ព្រះអង្គ صلوات الله عليه والسلام មិនធ្វើប្រការទាំងនេះទេ ។ ចូរនិយាយប្រាប់ឪពុកម្តាយអ្នកថាព្រះអង្គ صلوات الله عليه والسلام ធ្វើអ្វីពេលកើតមកភ្លាម ។ អ៊ីម៉ាំទាំងអស់ عليهم السلام ធ្វើដូចអ៊ីម៉ាំ ហុាសាន់ អុាស់ការី صلوات الله عليه والسلام ដែរ ។ ចូរអ្នកគូររូបអ្នកកំពុងក្រាបសំពះ (ស៊ូឃ្លូដ) អល់ឡោះហ្ម៍ عز وجل ។

# មេរៀនទី ១៥

## អ៊ីមុាំ មូហុាំម៉ាដ់ អាល់-ម៉ាស្ហ់ឌី صلوات الله عليه والسلام

អ៊ីមុាំ មូហុាំម៉ាដ់ អាល់-ម៉ាស្ហ់ឌី صلوات الله عليه والسلام ជាអ៊ីមុាំទី ១២ របស់យើង ។ ព្រះអង្គ صلوات الله عليه والسلام ជាអ៊ីមុាំរបស់សម័យបច្ចុប្បន្នយើងនេះ ។ ព្រោះតែអ៊ីមុាំ មូហុាំម៉ាដ់ អាល់-ម៉ាស្ហ់ឌី صلوات الله عليه والسلام នៅរស់នៅឡើយសព្វថ្ងៃនេះ បានជាយើងត្រូវឱនក្បាលហើយសូត្រស្វ៏ឡាវ៉ាត ពាល់ពេលដែលយើងថាព្រះនាមព្រះអង្គ صلوات الله عليه والسلام ជាការសម្ដែងសេចក្ដីគោរព ។

អល់ឡោះហ្វ៍ عزوجل បានសន្យានឹងមុស្លីមទាំងអស់ថា ព្រះអង្គ عزوجل នឹងមិនទុកឲ្យអ្នកណាមួយគ្មានអ្នកដឹកនាំទេ ។ អ្នកដឹកនាំយើងគឺអ៊ីមុាំទី ១២ អ៊ីមុាំ មូហុាំម៉ាដ់ អាល់-ម៉ាស្ហ់ឌី صلوات الله عليه والسلام ។

អ៊ីមុាំ មូហុាំម៉ាដ់ អាល់-ម៉ាស្ហ់ឌី صلوات الله عليه والسلام នៅក្នុងកុយ់បាស្ង់ ពោលគឺ ព្រះអង្គ صلوات الله عليه والسلام កំបាំងខ្លួន យើងមើលមិនឃើញព្រះអង្គ صلوات الله عليه والسلام ទេ ។ តែព្រះអង្គ صلوات الله عليه والسلام ឃើញយើងនិងដឹងទាំងអស់ពេលយើងត្រូវការជំនួយ ព្រះអង្គ صلوات الله عليه والسلام នឹងមកជួយយើង ។

អ្នកខ្លះថាអ៊ីមុាំកំបាំងខ្លួនមិនអាចជួយយើងបានទេ ។ ប្រៀបបាននឹងថ្ងៃបាំងពីក្រោយដុំពពកដែលនៅតែផ្ដល់កម្ដៅមកលើយើងនោះដែរ អ៊ីមុាំ صلوات الله عليه والسلام យើងនៅតែជួយយើងរហូត ។

ពេលអ្នកចង់បានអ្វីមួយ អ្នកត្រូវសូមតាមរយៈអ៊ីមុាំទី ១២ អ៊ីមុាំ មូហុាំម៉ាដ់ អាល់-ម៉ាស្ហ់ឌី صلوات الله عليه والسلام ព្រោះព្រះអង្គ صلوات الله عليه والسلام នៅជិតអល់ឡោះហ្វ៍ عزوجل ជាងយើង ។ អ៊ីនស្ហាអ៊ ័ អល់ឡោះហ្វ៍ عزوجل អល់ឡោះហ្វ៍ عزوجل នឹងបំពេញបំណងយើង ។

ចូរអ្នកចងចាំថា ប្រសិនបើបំណងអ្នកមិនបានសម្រេចទេនោះ មិនបានសេចក្ដីថាអល់ឡោះហ្វ៍ عزوجل មិនព្វអ្នកនោះទេ តែពីព្រោះមានតែអល់ឡោះហ្វ៍ عزوجل មួយគត់ដែលដឹងថាអ្វីល្អប្រសើរសម្រាប់អ្នក ។ ដែលព្រះអង្គ عزوجل មិនបំពេញបំណងអ្នកនោះ ព្រោះតែបំណងនោះអាចនាំមកនូវផលអាក្រក់ដល់អ្នក ។

ពេលវេលាដែលអ៊ីមុាំទី ១២ របស់យើងនឹងបង្ហាញខ្លួនប្រាកដជានឹងមកដល់ ។ មានតែអល់ឡោះហ្វ៍ عزوجل ទេដែលដឹងពេលវេលាច្បាស់លាស់ ។ អ៊ីមុាំ صلوات الله عليه والسلام យើងនឹងងើបឡើង ព្រះអង្គ صلوات الله عليه والسلام នឹងប្រយុទ្ធទល់នឹងមនុស្សអាក្រក់ នឹងមានសល់តែមនុស្ស

ល្អទេនៅក្នុងលោក ។

ឧត្តមគតិរឿងនេះគឺ អ្នកត្រូវធានាថាខ្លួនអ្នកនៅលើផ្លូវល្អដើម្បីនឹងប្រយុទ្ធនៅខាងអ៊ីមុាំទី ១២ របស់យើង អ៊ីមុាំ មូហ៊ាំម៉ាដ់ អាល់-ម៉ាស្ទ់ឌ្វី صلوات الله عليه والسلام មិនប្រយុទ្ធតទល់ព្រះអង្គ صلوات الله عليه والسلام ទេ ។

**លំហាត់ ១៥ក**

# អ៊ីមុាំ មូហុាំម៉ាដ្ញ់ អាល់-ម៉ាស្ទ់ឌី صلوات الله عليه والسلام

អ៊ីមុាំ មូហុាំម៉ាដ្ញ់ អាល់-ម៉ាស្ទ់ឌី صلوات الله عليه والسلام ប្រសូតនៅឯស្រុកសាម៉ាររ៉អ៊្ំ (ប្រទេស អ៊ីរ៉ាក់្វ) ថ្ងៃទី ១៥ ខែ ស្ហាក់្បុបាន ឆ្នាំ ២៥៥ សករាជហ្ចុ៊ីជ្ជរ៉ោះត៍ ។ ព្រះអង្គ صلوات الله عليه والسلام គង់ព្រះជន្មនៅឡើយ (សព្វថ្ងៃនេះព្រះអង្គ صلوات الله عليه والسلام មានព្រះជន្មាយុ ១១៥០ ឆ្នាំ) ។

ព្រះបិតា ៖
អ៊ីមុាំ ហ្ហាសាន់ អាល់-អាស្កការី صلوات الله عليه والسلام

មាតា ៖
ប៊ីប៊ី ណារយ៉ើស (نرجس)

អ៊ីមុាំ មូហុាំម៉ាដ្ញ់ អាល់-ម៉ាស្ទ់ឌី صلوات الله عليه والسلام

## លំហាត់ ១៥ខ

ចូរគូរអ្វីៗដែលអ្នកចង់ឲ្យអ៊ីម៉ាំទី ១២ សូមពីអល់ឡោះហ្ម៍عزّ وجلّឲ្យអ្នក ។

អាស់-សាឡាមុ អ៊ុឡៃគុម

ជូនចំពោះ អ៊ីម៉ាំ មូហ្ហាំម៉ាដ្ឋ អាល់-ម៉ាស្ទូឌីصلوات الله عليه والسلامជាទីគោរព ។

# រឿងទេវតាហ្វិត្រុសនិងអ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام

قَالَ: حَدَّثَنَا عَبْدُ اَللَّهِ بْنُ هِشَامٍ قَالَ: حَدَّثَنَا أَبُو اَلْحَسَنِ عَلِيُّ بْنُ مُوسَى بْنِ جَعْفَرِ بْنِ مُحَمَّدٍ عَنْ أَبِيهِ عَنْ جَدِّهِ عَنْ آبَائِهِ عَلَيْهِمُ اَلسَّلاَمُ عَنِ اَلنَّبِيِّ صَلَّى اَللَّهُ عَلَيْهِ وَ آلِهِ قَالَ: كَانَ مَلَكُ اَلْكَرُوبِيِّينَ يُقَالُ لَهُ فُطْرُسُ وَ كَانَ مِنَ اَللَّهِ عَزَّ وَ جَلَّ بِمَكَانٍ فَأَرْسَلَهُ بِرِسَالَةٍ فَأَبْطَأَ فَكَسَرَ جَنَاحَهُ فَأَلْقَاهُ بِجَزِيرَةٍ مِنْ جَزَائِرِ اَلْبَحْرِ فَلَمَّا وُلِدَ اَلْحُسَيْنُ بْنُ عَلِيٍّ عَلَيْهِ السَّلاَمُ أَرْسَلَ اَللَّهُ عَزَّ وَ جَلَّ جَبْرَئِيلَ فِي أَلْفٍ مِنَ اَلْمَلاَئِكَةِ يُهَنِّئُونَ رَسُولَ اَللَّهِ صَلَّى اَللَّهُ عَلَيْهِ وَ آلِهِ بِمَوْلُودٍ وَ يُخْبِرُونَهُ بِكَرَامَتِهِ عَلَى رَبِّهِ عَزَّ وَ جَلَّ فَمَرَّ جَبْرَئِيلُ بِذَلِكَ اَلْمَلَكِ فَكَانَ بَيْنَهُمَا خُلَّةٌ فَقَالَ فُطْرُسُ يَا رُوحَ اَللَّهِ اَلْأَمِينَ أَيْنَ تُرِيدُ؟ قَالَ إِنَّ هَذَا اَلنَّبِيَّ اَلتَّهَامِيَّ وَهَبَ اَللَّهُ عَزَّ وَ جَلَّ لَهُ وَلَداً اِسْتَبْشَرَ بِهِ أَهْلُ اَلسَّمَاوَاتِ وَ أَهْلُ اَلْأَرْضِ فَأَرْسَلَنِي اَللَّهُ تَعَالَى إِلَيْهِ أُهَنِّئُهُ وَ أُخْبِرُهُ بِكَرَامَتِهِ عَلَى رَبِّهِ عَزَّ وَ جَلَّ قَالَ هَلْ لَكَ أَنْ تَنْطَلِقَ بِي مَعَكَ إِلَيْهِ يَشْفَعُ لِي عِنْدَ رَبِّهِ فَإِنَّهُ سَخِيٌّ جَوَادٌ فَانْطَلَقَ اَلْمَلَكُ مَعَ جَبْرَئِيلَ عَلَيْهِ اَلسَّلاَمُ فَقَالَ إِنَّ هَذَا مَلَكٌ مِنَ اَلْمَلاَئِكَةِ اَلْكَرُوبِيِّينَ كَانَ لَهُ مِنَ اَللَّهِ تَعَالَى مَكَانٌ فَأَرْسَلَهُ بِرِسَالَةٍ فَأَبْطَأَ فَكَسَرَ جَنَاحَهُ وَ أَلْقَاهُ بِجَزِيرَةٍ مِنْ جَزَائِرِ اَلْبَحْرِ وَ قَدْ أَتَاكَ لِتَشْفَعَ لَهُ عِنْدَ رَبِّكَ قَالَ فَقَامَ اَلنَّبِيُّ صَلَّى اَللَّهُ عَلَيْهِ وَ آلِهِ فَصَلَّى رَكْعَتَيْنِ وَ دَعَا فِي آخِرِهِنَّ اَللَّهُمَّ إِنِّي أَسْأَلُكَ بِحَقِّ كُلِّ ذِي حَقٍّ عَلَيْكَ وَ بِحَقِّ مُحَمَّدٍ وَ أَهْلِ بَيْتِهِ أَنْ تَرُدَّ عَلَى فُطْرُسَ جَنَاحَهُ وَ تَسْتَجِيبَ لِنَبِيِّكَ وَ تَجْعَلَهُ آيَةً لِلْعَالَمِينَ فَاسْتَجَابَ اَللَّهُ تَعَالَى لِنَبِيِّهِ صَلَّى اَللَّهُ عَلَيْهِ وَ آلِهِ وَ أَوْحَى إِلَيْهِ أَنْ يَأْمُرَ فُطْرُسَ أَنْ يُمِرَّ جَنَاحَهُ عَلَى اَلْحُسَيْنِ عَلَيْهِ السَّلاَمُ فَقَالَ رَسُولُ اَللَّهِ لِفُطْرُسَ أَمْرِرْ جَنَاحَكَ اَلْكَسِيرَ عَلَى هَذَا اَلْمَوْلُودِ فَفَعَلَ فَسَبَّحَ فَأَصْبَحَ صَحِيحاً فَقَالَ اَلْحَمْدُ لِلَّهِ اَلَّذِي مَنَّ عَلَيَّ بِكَ يَا رَسُولَ اَللَّهِ فَقَالَ اَلنَّبِيُّ لِفُطْرُسَ أَيْنَ تُرِيدُ-؟ فَقَالَ إِنَّ جَبْرَئِيلَ أَخْبَرَنِي بِمَصْرَعِ هَذَا اَلْمَوْلُودِ وَ إِنِّي سَأَلْتُ رَبِّي أَنْ يَجْعَلَنِي خَلِيفَةً هُنَاكَ قَالَ فَذَلِكَ اَلْمَلَكُ مُوَكَّلٌ بِقَبْرِ اَلْحُسَيْنِ عَلَيْهِ السَّلاَمُ فَإِذَا تَرَحَّمَ عَبْدٌ عَلَى اَلْحُسَيْنِ أَوْ تَوَلَّى أَبَاهُ أَوْ نَصَرَهُ بِسَيْفٍ وَ لِسَانِهِ اِنْطَلَقَ ذَلِكَ اَلْمَلَكُ إِلَى قَبْرِ رَسُولِ اَللَّهِ صَلَّى اَللَّهُ عَلَيْهِ وَ آلِهِ فَيَقُولُ أَيُّهَا اَلنَّفْسُ اَلزَّكِيَّةُ فُلاَنُ بْنُ فُلاَنٍ بِبِلاَدِ كَذَا وَ كَذَا يَتَوَلَّى اَلْحُسَيْنَ وَ يَتَوَلَّى أَبَاهُ وَ نَصَرَهُ بِلِسَانِهِ وَ قَلْبِهِ وَ سَيْفِهِ قَالَ فَيُجِيبُهُ مَلَكٌ مُوَكَّلٌ بِالصَّلاَةِ عَلَى اَلنَّبِيِّ أَنْ بَلِّغْهُ عَنْ مُحَمَّدٍ اَلسَّلاَمَ وَ قُلْ لَهُ إِنْ مِتَّ عَلَى هَذَا فَأَنْتَ رَفِيقُهُ فِي اَلْجَنَّةِ . (بشارة المصطفى لشيعة المرتضى , الجزء ١ , الصفحة ٢١٩)

អ៊ុប់ឌុលឡោះហ៍ ប៊ិន ហ៊ីស្សាំមានប្រសាសន៍ថា អាប៊ូ អាល់-ហាសាន់ អ៊ុលី ប៊ិន មូសា ប៊ិន យ៉ាក្កុំហ្វារ ប៊ិន មូហាំម៉ាដ្ឋ (អាល់-រីដ្ហ៍ صلوات الله عليه والسلام) មានវចនៈតមកពីព្រះបិតាព្រះអង្គ صلوات الله عليه والسلام ដែលមានវចនៈតមកពីព្រះអយ្យកោ صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام ដែលមានវចនៈតមកពីព្រះបិតា صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام ដែលមានវចនៈតមកពីព្រះសាស្តា صلى الله عليه وآله وسلم ដែលមានព្រះវចនៈថា៖ "ហ្វិត្រុសជាព្រះអគ្គទេវតាជាន់ខ្ពស់មួយអង្គ ។ អល់ឡោះហ៍ عز وجل បានចាត់បញ្ជូនព្រះអង្គទៅបំពេញបេសកកម្មនៅកន្លែងនីមួយ តែព្រះអង្គបណ្ដែតបណ្ដោយ ។ ដូច្នេះអល់ឡោះហ៍ عز وجل បានបំបាក់ស្លាបហ្វិត្រុស ហើយចោលព្រះអង្គឲ្យនៅលើកោះមួយ ។ ពេល[អ៊ីម៉ាំ]ហ៊ូសែន៍ صلوات الله عليه والسلام ប្រសូត អល់ឡោះហ៍ عز وجل បាន

ចាត់បញ្ជូនយ្ជីបរ៉អ៊ីលصلوات الله عليه والسلامជាមួយទេវតា ១០០០ អង្គទៅសម្ដែងការអបអរសាទរចំពោះរ៉ស៊ូលុលឡោះហ្វ៎صلى الله عليه وآله وسلمនាថ្ងៃប្រសូត[អ៊ីម៉ាំ]ហ៊្ហូសែន៍صلوات الله عليه والسلام និងប្រាប់ព្រះអង្គصلى الله عليه وآله وسلمឲ្យជ្រាបអំពីឋានៈរបស់[អ៊ីម៉ាំ]ហ៊្ហូសែន៍صلوات الله عليه والسلام ។ ពេលយ្ជីបរ៉អ៊ីលعليه السلامធ្វើដំណើរតាមនោះក៏បានជួបហ៊្វុត្តរុស ហ៊្វុត្តរុសបានសួរព្រះអង្គعليه السلامថា៖ "ព្រះអង្គعليه السلامយាងទៅណា ?" យ្ជីបរ៉អ៊ីលعليه السلامបានតបថា៖ "អល់ឡោះហ្វ៎عزوجلបានព្រះរាជទានព្រះរាជបុត្រាមួយអង្គឲ្យព្រះសាស្ដាصلى الله عليه وآله وسلمព្រះអង្គعزوجل ។ ប្រជានិករក្នុងពិភពលោកទាំងអស់ត្រេកអរណាស់អំពីដំណឹងនេះ ។ ដូច្នេះអល់ឡោះហ្វ៎عزوجلចាត់បញ្ជូនខ្ញុំعليه السلامទៅសម្ដែងការអបអរសាទរចំពោះព្រះអង្គصلى الله عليه وآله وسلم និងប្រាប់ព្រះអង្គصلى الله عليه وآله وسلمឲ្យជ្រាបថាឋានៈរបស់ព្រះរាជបុត្រព្រះអង្គصلى الله عليه وآله وسلمនោះថ្កើងថ្កានប៉ុណ្ណាសម្រាប់អល់ឡោះហ្វ៎عزوجل ។" ហ៊្វុត្តរុសបានថា៖ "តើព្រះអង្គعليه السلامអាចនាំទូលបង្គំទៅជួបព្រះសាស្ដាصلى الله عليه وآله وسلم ជាមួយព្រះអង្គعليه السلامផងបានទេ ដើម្បីទូលបង្គំនឹងសូមឲ្យព្រះអង្គصلى الله عليه وآله وسلمជួយធ្វើអន្តរាគមន៍ឲ្យទូលបង្គំពីព្រោះព្រះអង្គصلى الله عليه وآله وسلمមានព្រះហឫទ័យទូលាយ ។" យ្ជីបរ៉អ៊ីលعليه السلامក៏បាននាំទេវតាទៅជួបព្រះសាសនៈទូតصلى الله عليه وآله وسلمអល់ឡោះហ្វ៎عزوجل ហើយទូលថា៖ "ហ៊្វុត្តរុសធ្លាប់ជាព្រះអគ្គទេវតាថ្នាក់ខ្ពស់មួយអង្គ ។ អល់ឡោះហ្វ៎عزوجلបានចាត់បញ្ជូនព្រះអង្គទៅបំពេញបេសកកម្មមួយនាកន្លែងនីមួយតែព្រះអង្គយឺតយ៉ាវ ។ ហេតុដូច្នេះហើយបានជាអល់ឡោះហ្វ៎عزوجلកាច់បំបាក់ស្លាបព្រះអង្គ ហើយបានចោលព្រះអង្គនៅលើកោះមួយ ។ ហ៊្វុត្តរុសមករកព្រះអង្គصلى الله عليه وآله وسلمដើម្បីសូមឲ្យព្រះអង្គصلى الله عليه وآله وسلمជួយធ្វើអន្តរាគមន៍ឲ្យព្រះអង្គផង ។ ព្រះសាសនៈទូតصلى الله عليه وآله وسلمអល់ឡោះហ្វ៎عزوجلបានស្ទាបឡាត្ធពីរ៉ក់អាត់ រួចហើយព្រះអង្គصلى الله عليه وآله وسلمបានទូលអល់ឡោះហ្វ៎عزوجلថា៖ "អល់ឡោះហ្វ៎عزوجلអើយ ទូលព្រះបង្គំជាខ្ញុំបួងសួងព្រះអង្គعزوجل ក្នុងនាមបុគ្គលដែលព្រះអង្គعزوجلបើកសិទ្ធិឲ្យ ទូលព្រះបង្គំជាខ្ញុំصلى الله عليه وآله وسلمបួងសួងព្រះអង្គعزوجل ក្នុងនាមព្រះរាជសិទ្ធិរបស់មូហាំម៉ាដ់صلى الله عليه وآله وسلم និងព្រះរាជកុលដ្ឋានរបស់មូហាំម៉ាដ់صلى الله عليه وآله وسلم សូមព្រះអង្គعزوجلទ្រង់ព្រះមេត្តាព្រះរាជទានស្លាបឲ្យហ៊្វុត្តរុសវិញ ព្រះបពិត្រ ។ សូមព្រះអង្គعزوجلឲ្យការបួងសួងរបស់ព្រះសាស្ដាصلى الله عليه وآله وسلمព្រះអង្គعزوجلបានសម្រេចដូចប្រាថ្នា និងសូមព្រះអង្គعزوجلទុកព្រឹត្តិការណ៍នេះជាភ័ស្តុតាងសម្រាប់លោកទាំងឮង ព្រះមហាបពិត្រ ។" អល់ឡោះហ្វ៎عزوجلព្រមទទួលការបួងសួងរបស់ព្រះសាស្ដាصلى الله عليه وآله وسلم ហើយបានបើកឲ្យព្រះអង្គصلى الله عليه وآله وسلمដឹងថា ឲ្យហ៊្វុត្តរុសទៅប៉ះ[អ៊ីម៉ាំ]ហ៊្ហូសែន៍صلوات الله عليه والسلامដោយស្លាបបាក់របស់ព្រះអង្គនោះ ។ ព្រះសាស្ដាصلى الله عليه وآله وسلمបានប្រាប់ហ៊្វុត្តរុសថា៖ "ចូរព្រះអង្គត្រដុស

ស្លាបបាក់នឹងហ្វ៊ូសៃន៍صلوات الله عليه والسلامទៅ" ហ្វ៊ុត្រុសក៏បានធ្វើដូចព្រះអង្គصلى الله عليه وآله وسلمប្រាប់ ស្លាបហ្វ៊ុត្រុសបានជាវិញ ។ ហ្វ៊ុត្រុសបានទូលថា៖ "សូមថ្វាយសេចក្ដីសរសើរចំពោះព្រះជាម្ចាស់عز وجلដែលព្រះរាជទានព្រះមេត្តាប្រោសប្រណីមកលើទូលព្រះបង្គំជាខ្ញុំ តាមរយៈព្រះអង្គصلى الله عليه وآله وسلم ឱព្រះសាសនៈទូតصلى الله عليه وآله وسلمអល់ឡោះហ៍عز وجلអើយ ។" ព្រះសាស្ដាصلى الله عليه وآله وسلمបានសួរហ្វ៊ុត្រុសថា៖ "តើព្រះអង្គعليه السلامទៅណាពេលនេះ ?" ហ្វ៊ុត្រុសបានតបថា៖ "ឈ្ញីបរ៉អ៊ីលعليه السلامបានប្រាប់ទូលបង្គំ អំពីដែនដីដែលព្រះរាជទារកអង្គនេះនឹងត្រូវគេធ្វើឃាត ។ ដូច្នេះទូលបង្គំបានសូមឲ្យព្រះជាម្ចាស់عز وجلទូលបង្គំតែងតាំងទូលបង្គំជាខ្ញុំលិហ្សរបស់ហ្វ៊ូសៃន៍صلوات الله عليه والسلامនៅលើដែនដីនោះ ។" ព្រះសាស្ដាصلى الله عليه وآله وسلمមានព្រះវចនៈបន្តថា បន្ទាប់ពីនោះទេវតាដែលជាអ្នកទទួលភារកិច្ចស៊្វឡាវ៉ាតនឹងឆ្លើយតបហ្វ៊ុត្រុសថា៖ "ចូរអ្នកនាំសាឡាមរបស់មូហ៊ាំម៉ាដ់صلى الله عليه وآله وسلمទៅឲ្យបាវនេះ ហើយប្រាប់បាវនោះថា បើគាត់ស្លាប់ក្នុងជំនឿនេះ អ្នក (គឺហ្វ៊ុត្រុស) នឹងនាំគាត់ទៅកាន់ឋានសួគ៌ ។"

(بشارة المصطفى لشيعة المرتضى , الجزء ١ , الصفحة ٢١٩)

១៥/០២/២០២១